ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសវនកម្មជាតិ

លេខ:..................អសជ/.....

# របាយការណ៍សវនកម្មលើកិច្ចប្រតិបត្តិការ

# «ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ»

# របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**ការិយបរិច្ឆេទ២០១៩ - ២០២១**

អគារលេខ ៥ ផ្លូវឌួងងៀប៣ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ

# 5, St. Duong Ngeab 3, Sangkat Tekthla, Khan Sensok, Phnom Penh, CAMBODIA

Tel:(855-23) 885 900, (855-12) 737 622 Fax: (855-23) 885 900

E-mail: naakh@naa.gov.kh website: www.naa.gov.kh

# សេចក្ដីសង្ខេប

សវនកម្មលើកិច្ចប្រតិបត្តិការក្រោមប្រធានបទ «ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ» ត្រូវបានជ្រើសរើសយកមកធ្វើសវនកម្ម ដោយសារការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ គឺជាវិស័យមួយដែលរាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់អភិវឌ្ឍន៍ ដើម្បីអាចបង្កើតបាននូវធនធានមនុស្ស ដែលមានសមត្ថភាព ជំនាញច្បាស់លាស់ និងគុណភាពខ្ពស់ សម្រាប់ចូលរួមសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចរយៈពេលមធ្យម និងវែង និងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។ គុណភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវបានកត់សម្គាល់ថា មិនទាន់បំពេញបានតាមតម្រូវការទីផ្សារ ដោយសារតែមានការខ្វះខាតហេដ្ឋារចនាសម្ព័ន្ធ ឧបករណ៍ សម្ភារ មន្ទីរពិសោធន៍ ឯកសារបច្ចេកទេស បុគ្គលិក/គ្រូជំនាញ ដែលមានបទពិសោធន៍ និងកម្មវិធីសិក្សាដែលឆ្លើយតបទៅនឹងទីផ្សារការងារ។ ការចូលរួម និងសហការពីវិស័យឯកជន និងភាគីពាក់ព័ន្ធក្នុងការរៀបចំកម្មវិធី និងការផ្តល់ឧបត្ថម្ភនៅមានកម្រិត ដែលធ្វើឱ្យខ្វះធនធានហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍវិស័យអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

គោលបំណងរួមនៃការធ្វើសវនកម្មនេះគឺដើម្បីវាយតម្លៃប្រសិទ្ធភាព និងប្រសិទ្ធផលនៃការពង្រឹងគុណភាព និងការពង្រីកវិស័យអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ ព្រមទាំងយន្តការនៃការធានាបានធនធាន និងសមត្ថភាពដើម្បីអភិវឌ្ឍវិស័យអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ការធ្វើសវនកម្មនេះ ពិនិត្យ និងវាយតម្លៃលើកម្មវិធី និងសកម្មភាពដែលអនុវត្តដោយអគ្គនាយកដ្ឋានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ចាប់ពីឆ្នាំ២០១៩ រហូតដល់ឆ្នាំ២០២១ ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានខិតខំធ្វើទំនើបកម្មប្រព័ន្ធអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដោយយកចិត្តទុកដាក់លើការបង្កើនគុណភាពការបណ្តុះបណ្តាលតាមរយៈការអភិវឌ្ឍកញ្ចប់ស្តង់ដាបណ្តុះបណ្តាល, ការធ្វើវិក្រឹតការគ្រូបច្ចេកទេស, ការរៀបចំហេដ្ឋារចនាសម្ព័ន្ធគ្រឹះស្ថានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ព្រមទាំងការត្រួតពិនិត្យ និងវាយតម្លៃគុណភាព និងប្រសិទ្ធភាពនៅក្នុងអំឡុងពេល និងក្រោយពេលបណ្តុះបណ្តាល។ សម្រាប់ការពង្រីកការបណ្តុះបណ្តាល ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានផ្តោតការយកចិត្តទុកដាក់លើភាពសមធម៌ ដោយបានខិតខំផ្សព្វផ្សាយ និងជ្រើសរើសជនងាយរងគ្រោះ ចូលរៀន ដើម្បីអាចឱ្យសម្រេចបានតាមបរិមាណដែលបានកំណត់សម្រាប់កម្រិតសិក្សានីមួយៗ។ ក្នុងការធានានិរន្តរភាពប្រព័ន្ធអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានខិតខំអនុវត្ត តួនាទី និងភារកិច្ចប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ព្រមទាំងស្វែងរកកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូជាមួយវិស័យឯកជន និងដៃគូអភិវឌ្ឍន៍ ដើម្បីទទួលបាននូវធនធាន និងសមត្ថភាពគ្រប់គ្រាន់។

ទន្ទឹមនឹងនេះ ក្នុងដំណើរការនៃការអភិវឌ្ឍវិស័យអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅមានចំណុចខ្វះខាត ដែលត្រូវកែលម្អមួយចំនួន ដូចខាងក្រោម៖

- ការពង្រឹងគុណភាពវិស័យអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅមានកម្រិត ដូចជា ការអភិវឌ្ឍកញ្ចប់ស្តង់ដាបណ្តុះបណ្តាលផ្អែកលើសមត្ថភាពផ្អែកតាមក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជាពុំទាន់សមស្របតាមផែនការ, ការអនុវត្តកញ្ចប់ស្តង់ដាបណ្តុះបណ្តាលនៅមានកម្រិត, ការលើកកម្ពស់សមត្ថភាពគ្រូបច្ចេកទេសនៅមានកម្រិត, ការតាមដានត្រួតពិនិត្យ និងវាយតម្លៃសមត្ថភាពគ្រូបច្ចេកទេសពុំទាន់អនុវត្តឱ្យមានលក្ខណៈជាប្រព័ន្ធ, ហេដ្ឋារចនាសម្ព័ន្ធ និងការបំពាក់ឧបករណ៍ បរិក្ខារ និងសម្ភារបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានពុំទាន់គ្រប់គ្រាន់ និងទំនើបកម្ម ហើយការត្រួតពិនិត្យ និងវាយតម្លៃគុណភាព និងការ

ត្រួតពិនិត្យ និងវាយតម្លៃគុណភាពក្នុងអំឡុងពេល និងក្រោយពេលបណ្តុះបណ្តាលពុំទាន់អនុវត្តបានទៀងទាត់ និងមានប្រសិទ្ធភាព។

- ការពង្រីកការបណ្តុះបណ្តាលជាពិសេសការផ្សព្វផ្សាយរកចំនួនសិក្ខាកាមចុះឈ្មោះចូលរៀនវគ្គខ្លី ពុំទាន់សម្រេចបានតាមបរិមាណដែលបានគ្រោងទុក ចំណែកឯការបង្កើតប្រព័ន្ធតាមដានត្រួតពិនិត្យ និងរាយការណ៍អំពីវិស័យអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅពុំទាន់មានប្រសិទ្ធភាព ដូចជា សមត្ថភាពប្រើប្រាស់ប្រព័ន្ធ TVET-MIS របស់មន្ត្រីទទួលបន្ទុកនៅតាមគ្រឹះស្ថានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈមួយចំនួននៅមានកម្រិត ហើយដំណើរការនៃការត្រួតពិនិត្យ និងរាយការណ៍ដែលមានការចូលរួមពីភាគីពាក់ព័ន្ធក៏នៅមានកម្រិត។
- ការធានាបាននូវធនធាន និងសមត្ថភាព ដើម្បីអភិវឌ្ឍន៍ និងធានានិរន្តរភាពវិស័យអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅពុំទាន់បានគ្រប់គ្រាន់នៅឡើយ ដូចជា ការអនុវត្តតួនាទី និងភារកិច្ចរបស់ការិយាល័យមួយចំនួនតូច នៃនាយកដ្ឋានក្រោមចំណុះអគ្គនាយកដ្ឋានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៅពុំទាន់បានគ្រប់ជ្រុងជ្រោយ និងការជំរុញកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូជាមួយវិស័យឯកជន និងដៃគូអភិវឌ្ឍន៍ ដើម្បីធានាបានធនធាន និងសមត្ថភាពគ្រប់គ្រាន់នៅមានកម្រិត។

ឆ្លងតាមលទ្ធផល និងសេចក្តីសន្និដ្ឋាននៃការធ្វើសវនកម្មលើកិច្ចប្រតិបត្តិការក្រោមប្រធានបទ «ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ» នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អាជ្ញាធរសវនកម្មជាតិ បានផ្តល់នូវអនុសាសន៍មួយចំនួនដូចខាងក្រោម៖

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គួរពន្លឿនការរៀបចំកញ្ចប់ស្តង់ដាបណ្តុះបណ្តាល, ជំរុញការអនុវត្តយន្តការចែករំលែកធនធាន និងការអនុវត្តផែនការមេសម្រាប់អភិវឌ្ឍគ្រឹះស្ថានការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ទៅតាមផែនការដែលបានគ្រោងទុក។ ក្រសួងក៏គួរមានយន្តការជួយដោះស្រាយបញ្ហាប្រឈម ដើម្បីជួយរក្សាបរិមាណគ្រូបច្ចេកទេសសមស្រប និងការលើកទឹកចិត្តគ្រូ, រៀបចំឱ្យមានប្រព័ន្ធត្រួតពិនិត្យ តាមដាន និងវាយតម្លៃការបណ្តុះបណ្តាលរបស់គ្រូ និងពង្រីកវិសាលភាពនៃការវាយតម្លៃក្នុងអំឡុងពេលបណ្តុះបណ្តាល ព្រមទាំងអនុវត្តឱ្យបានទៀតទាត់នូវការវាយតម្លៃក្រោយការបណ្តុះបណ្តាល។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈគួរពិនិត្យលទ្ធភាពរៀបចំវគ្គបណ្តុះបណ្តាលដែលស្របតាមតម្រូវការរបស់សហគមន៍ និងបណ្តុះបណ្តាលមន្ត្រី ឬជនបង្គោលទទួលបន្ទុក ប្រព័ន្ធ TVET-MIS ឱ្យបានទៀងទាត់ និងតាមការចាំបាច់ ដើម្បីបង្កើនសមត្ថភាពក្នុងការបញ្ចូល និងការទាញទិន្នន័យសម្រាប់ប្រើប្រាស់។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏គួរជំរុញឱ្យការរៀបចំកិច្ចប្រជុំតាមដាន ត្រួតពិនិត្យការងាររបស់គណៈកម្មាធិការ, អនុគណៈកម្មការ និងក្រុមការងារពាក់ព័ន្ធ ឱ្យបានទៅតាមចំនួន និងពេលវេលាកំណត់។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គួរសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធផ្លាស់ប្តូរព័ត៌មាន, ស្វែងរកធនធាន និងអ្នកជំនាញបច្ចេកទេសដើម្បីអាចឱ្យអង្គភាពក្រោមឱវាទអាចអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនឱ្យបានមានប្រសិទ្ធភាព និងគួរពន្លឿនការរៀបចំច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ព្រមទាំងផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដើម្បីជំរុញការចូលរួមចំណែករបស់វិស័យឯកជនក្នុងការអភិវឌ្ឍវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឱ្យស្របតាមតម្រូវការកម្លាំងពលកម្មនៅលើទីផ្សារការងារ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានផ្តល់មតិឆ្លើយបំភ្លឺលើលទ្ធផលសវនកម្មលើកិច្ចប្រតិបត្តិការក្រោមប្រធានបទ «ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ» សម្រាប់ការិយបរិច្ឆេទ២០១៩-២០២១ ដូចខាងក្រោម៖

- ក្រសួងទទួលយកអនុសាសន៍នេះ។ ក្រសួងនឹងខិតខំកៀរគរធនធាន និងស្វែងរកដៃគូអភិវឌ្ឍន៍គាំទ្របន្ថែមទៀត ដល់ការរៀបចំអភិវឌ្ឍកញ្ចប់ស្តង់ដាបណ្តុះបណ្តាល ផ្អែកលើសមត្ថភាពឱ្យអស់លទ្ធភាព។ ក្រសួងក៏នឹងខិតខំជំរុញការប្រើប្រាស់កញ្ចប់ស្តង់ដាបណ្តុះបណ្តាលផ្អែកលើសមត្ថភាព និងពង្រឹងសមត្ថភាពគ្រូបច្ចេកទេសឱ្យកាន់តែមានគុណភាព។ ក្រសួងនឹងខិតខំរករកវិធីដោះស្រាយបញ្ហាប្រឈមលើបរិមាណគ្រូ និងការលើកទឹកគ្រូ ហើយក្រសួងនឹងខិតខំពង្រឹងប្រព័ន្ធអធិការកិច្ចគ្រូបច្ចេកទេសបន្ថែមទៀត។ ក្រសួងនឹងបង្កើនការវិនិយោគ ពីធនធានថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍សាងសង់បន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រួមមាន អគារសិក្សា អន្តេវាសិកដ្ឋាន និងរោងជាងបន្ទប់ពិសោធន៍/និងបំពាក់ឧបករណ៍ សម្ភារ បរិក្ខារឱ្យបានគ្រប់គ្រាន់នៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ក្រសួងនឹងខិតខំពង្រឹងការត្រួតពិនិត្យ និងវាយតម្លៃគុណភាពបណ្តុះបណ្តាលបន្ថែមទៀត។
- ការបណ្តុះបណ្តាលវគ្គខ្លីក្រៅប្រព័ន្ធទាបជាងផែនការ ដោយសារក្រសួងត្រូវផ្លាស់ប្តូរផែនការបណ្តុះបណ្តាលដោយផ្តល់អាទិភាពទៅវគ្គវែង ដែលគាំទ្រដល់គោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មរបស់រាជរដ្ឋាភិបាល។ ក្រសួងតែងតែគិតគូរ និងផ្តល់អាទិភាពដល់ការបណ្តុះបណ្តាលជូនស្ត្រី យុវជនមកពីគ្រួសារក្រីក្រ ជនងាយរងគ្រោះ ជនជាតិដើមភាគតិច និងជនចំណាកស្រុក។ ក្រសួងទទួលយកអនុសាសន៍ ដោយនឹងធ្វើឱ្យប្រព័ន្ធ TVET-MIS ត្រូវបានអនុវត្ត និងប្រើប្រាស់ជាប្រយោជន៍ដល់គ្រប់ភាគីពាក់ព័ន្ធ ព្រមទាំងជំរុញឱ្យអនុវត្តបែបប្រជុំឱ្យបានទៀងទាត់។
- ក្រសួងទទួលយកអនុសាសន៍នេះ។ ក្រសួងនឹងពិនិត្យកែសម្រួលតួនាទី និងភារកិច្ចតាមការិយាល័យជំនាញមួយចំនួនឱ្យសមស្របនឹងស្ថានភាពបច្ចុប្បន្ន និងអនាគត។ ក្រសួងនឹងរៀបចំបង្កើតកិច្ចសហប្រតិបត្តិការរវាងរដ្ឋ និងឯកជនឱ្យកាន់តែជិតស្និទ្ធ ដើម្បីជានានិរន្តរភាពវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនិងលើកទឹកចិត្តដល់សហគ្រាស គ្រឹះស្ថាន ដៃគូអភិវឌ្ឍន៍ ដែលបានសហការ និងចូលរួមអភិវឌ្ឍវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។